បទឧទ្ទេសនាម
របស់
បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្នុងឱកាសពិភាក្សា
សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦

រដ្ឋសភា, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥

-សូមគោរពសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់,

-សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណា-ចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់,

-សូមគោរពឯកឧត្តមបណ្ឌិតអនុប្រធានទី ២ នៃរដ្ឋសភា,

-សូមគោរពសម្តេច, ឯកឧត្តម, លោកជំទាវ សមាជិក សមាជិកា នៃរដ្ឋសភា និងអង្គរដ្ឋសភាដ៏ឧត្តុង្គឧត្តម!

តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំបាទសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា, គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ធនាគារ និងសវនកម្មនៃរដ្ឋសភា និង អង្គរដ្ឋសភាទាំងមូល ដែលបានចាត់ការយ៉ាងរួសរាន់ និង អនុម័តដាក់ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦** ចូលក្នុងរបៀបវារៈរបស់ខ្លួន ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភានាថ្ងៃនេះ។ ជាមួយនេះ, ខ្ញុំបាទសូមសំដែងអំណរគុណដោយឡែកចំពោះ **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី ២) នៃរដ្ឋសភា ដែលបានចាប់ដំណើរការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់នេះជាមួយសមាជិក សមាជិកា នៃគណៈកម្មការទី ២ និងដោយមានការចូលរួមពីគណៈកម្មការទាំងអស់នៃរដ្ឋសភា ដើម្បីធ្វើឲ្យសេចក្តីព្រាងច្បាប់នេះឈានចូលដល់សម័យប្រជុំពេញអង្គរដ្ឋសភា ដូចដែលឯកឧត្តមប្រធានគណៈកម្មការទី ២ នៃរដ្ឋសភា បានធ្វើរបាយការណ៍ដ៏ក្បោះក្បាយជូនអង្គរដ្ឋសភាជ្រាបអម្បាញ់មិញនេះ។ អាស្រ័យដោយរាជរដ្ឋាភិបាលបាន

រៀបចំសេចក្តីថ្លែងហេតុពិស្តារមួយ គោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និង អង្គសភា រួចហើយហើយ **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** ក្នុងនាមគណៈកម្មការទី២ នៃរដ្ឋសភា ក៏បានរាយ-ការណ៍លម្អិតបន្ថែមទៀតជូនអង្គរដ្ឋសភាអម្បាញ់មិញនេះហើយដែរ រួមទាំងអំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាពរួម និងរចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះផង, ដូច្នេះ នៅពេលនេះខ្ញុំបាទសូមអនុញ្ញាតធ្វើបទឧទ្ទេសនាមដោយសង្ខេបខ្លះដើម្បីចំណេញពេល។ យ៉ាងណាក៏-ដោយ, ខ្ញុំបាទគោរពសុំការអធ្យាស្រ័យជាមុន ចំពោះករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញក្នុងគោលដៅគូសបញ្ជាក់ ឬសង្កត់ធ្ងន់បន្ថែម ឬសម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេសនាមនេះ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** បានរាយ-ការណ៍ជូនអង្គរដ្ឋសភាមុននេះ។

I - អំពីបរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៦

ជារួម, កម្ពុជានៅតែអាចបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ ក៏ប៉ុន្តែ ការរៀបចំថវិកាឆ្នាំ ២០១៦ នេះ ស្ថិតក្នុងបរិការណ៍ដែលកម្ពុជាត្រូវប្រឈមនឹងហានិភ័យពីកត្តាខាងក្រៅ និងកត្តាខាងក្នុងមួយចំនួន ដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ហើយជាយថាហេតុក៏អាចធ្វើឱ្យប៉ះពាល់ដល់ការប្រមូលចំណូលគ្រប់ប្រភេទផងដែរ ដូចដែលឯកឧត្តមប្រធានគណៈកម្មការទី ២ បានលើកឡើងរួចហើយ។

ទោះបីស្ថិតក្នុងបរិការណ៍មួយដែលមានបញ្ហាប្រឈម និងហានិភ័យបែបនេះក្តី, ក៏ប៉ុន្តែសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានរៀបចំឡើង ប្រកបដោយមហិច្ឆតា ដើម្បីបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល នីតិកាលទី ៥ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ ប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ឆ្ពោះទៅរកការសម្រេចគោលដៅសំខាន់ៗបន្ថែមទៀត នៃកម្មវិធីនយោបាយរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងដើម្បីពន្លឿនការអនុវត្តកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗជាពិសេស ការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ, ថវិកាឆ្នាំ ២០១៦ ក៏ត្រូវបានរៀបចំឡើង ក្នុងគោលបំណងបន្តធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយគុណភាព, បរិយាប័ន្ន និងមានភាពធន់ខ្ពស់ និង ដើម្បីគាំទ្រដល់ដំណើរសមាហរណកម្មរបស់កម្ពុជានៅក្នុងក្របខណ្ឌពិភពលោក និងក្របខណ្ឌតំបន់ ជាពិសេស ការចាប់ផ្តើមនៃសហគមន៍សេដ្ឋកិច្ចអាស៊ាននៅដើមឆ្នាំ ២០១៦ ខាងមុខ

រួមទាំងការគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ ដែលជាយុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិផងដែរ។

ក្នុងន័យនេះ ឆ្នាំ ២០១៦ ត្រូវតែជាឆ្នាំនៃការប្រមូលពួតផ្តុំនូវកម្លាំង និងធនធានសំដៅសម្រេចឱ្យបាននូវសមិទ្ធផលសំខាន់ៗបន្ថែមទៀត ដើម្បីធានាបាននូវដំណើរផ្លាស់ប្តូរមួយ ឆ្ពោះទៅរកការអភិវឌ្ឍ ប្រកបដោយគុណភាព និងចីរភាព។

II - អំពីគោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០១៦

ដើម្បីគោលដៅខាងលើ, ក្របខណ្ឌថវិកាឆ្នាំ ២០១៦ ត្រូវបានរៀបចំឡើង ដោយឈរលើ **គោលការណ៍សំខាន់ៗ** ដូចខាងក្រោម ៖

១-ការជំរុញបង្កើនចំណូលថវិកាឱ្យបានខ្ពស់ ដើម្បីឆ្លើយតបទៅនឹងមហិច្ឆតាចំណាយក្នុងការបន្តអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសគឺ គោលនយោបាយដំឡើងបៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងកម្មវិធីកែ-ទម្រង់ស៊ីជម្រៅដែលកំពុងត្រូវបានអនុវត្តយ៉ាងសកម្ម។

២-ការកំណត់អាទិភាព ដោយផ្អែកទៅតាមលទ្ធភាពនៃថវិកា តាមរយៈការសម្រួចប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្តល់អាទិភាពស្របតាមគោលនយោបាយរួមរបស់រាជ-រដ្ឋាភិបាលដែលត្រូវឆ្លើយឆ្លងគ្នាជាមួយនឹងអាទិភាពនៃកម្មវិធី និងសកម្មភាពចាំបាច់នានាដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ។ គួរគូសបញ្ជាក់ថា ស្របតាម **ឯកសារទស្សនាទាន ស្តីពីទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០** គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវអនុវត្តថវិកាកម្មវិធី-ពេញលេញ នៅឆ្នាំ ២០១៨។ ក្នុងក្របខ័ណ្ឌនៃថវិកាកម្មវិធី **ការរៀបចំ និងការវិភាជថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ ត្រូវផ្អែកលើរចនាសម្ព័ន្ធគោលនយោបាយរៀងៗខ្លួន** ពោលគឺផ្អែកលើគោលបំណងគោលនយោបាយ, កម្មវិធី, អនុកម្មវិធី និងចង្កោមសកម្មភាព ដោយមានការទទួលខុសត្រូវច្បាស់លាស់ ហើយដែលកម្រិតនីមួយៗ សុទ្ធតែមានសូចនាករសម្រាប់វាស់វែងលទ្ធផល និងសមិទ្ធកម្ម។ នៅឆ្នាំ ២០១៥ នេះ, រាជរដ្ឋាភិបាលបានដាក់ក្រសួង ស្ថាប័ន ចំនួន ១០ ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងដាក់ចំនួន ១៥ ក្រសួងស្ថាប័នបន្ថែមទៀត ឱ្យអនុវត្តនៅឆ្នាំ ២០១៦។ ដូចនេះ បើពិនិត្យលើចំណាយចរន្តនៃថវិកាថ្នាក់ជាតិ តាមកម្មវិធីវិញ ឃើញថា ចំណាយថវិកាកម្មវិធីនៅឆ្នាំ ២០១៦ មានសមាមាត្រចំនួន ៥៦,៥៥% ហើយ នៃចំណាយចរន្តថវិកាថ្នាក់ជាតិសរុប។

៣-ការផ្តោតការយកចិត្តទុកដាក់លើធនធានមនុស្ស តាមរយៈការត្បិតត្បៀតចំណាយលើការទិញ ឬ/និងចំណាយលើសកម្មភាពដែលមិនសូវចាំបាច់ ដើម្បីសន្សំថវិកាសម្រាប់ចំណាយលើធនធានមនុស្ស ដែលទទួលខុសត្រូវក្នុងការអនុវត្តការងារផ្ទាល់។

៤-ការផ្ទេរថវិកាឱ្យដល់អង្គភាពដែលអនុវត្តការងារផ្ទាល់ នៅក្រោមឱវាទរបស់ក្រសួងស្ថាប័ននានា, ទាំងនៅរដ្ឋបាលកណ្តាល ទាំងនៅមូលដ្ឋាន, ដើម្បីលើកកម្ពស់ប្រសិទ្ធភាពចំណាយ ជាពិសេស ធានាបាននូវភាពទាន់ពេលវេលា និងមានការទទួលខុសត្រូវច្បាស់លាស់នៅក្នុងការគ្រប់គ្រង និងចាត់ចែងអនុវត្តថវិកា។

៥-ការគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ, បរិមាណ, និងគុណភាព ដើម្បីកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី និងសកម្មភាពនានា ចៀសវាងការលើកគម្រោងចំណាយមិនសូវច្បាស់លាស់, ដែលធ្វើឱ្យការវិភាជថវិកាមិនសូវមានប្រសិទ្ធភាព ហើយខ្វះខាតថវិកានៅពេលអនុវត្ត។

៦-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការវិភាជថវិកា តាមរយៈការរឹតត្បិតលើការស្នើសុំបង្កើនចំណាយ ចំពោះក្រសួង ស្ថាប័នណា ដែលការប្រមូលចំណូលមិនអាចសម្រេចបានលទ្ធផលល្អតាមការរំពឹងទុក សមស្របតាមសក្តានុពលជាក់ស្តែង ឬ មិនបានផ្តល់ការយកចិត្តទុកដាក់ហ្មត់ចត់ពេញលេញដល់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឬមានការគ្រប់គ្រងធូររលុង។

III - អំពីក្របខណ្ឌថវិកាឆ្នាំ ២០១៦

ឈរលើគោលការណ៍ដូចបានជម្រាបខាងលើ ក៏ដូចជា ក្នុងក្របខណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៧% ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និងដោយឈរលើមូលដ្ឋាននៃលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូល ពិសេសចំណូលគយ និងចំណូលពន្ធដារឆ្នាំ ២០១៤ និង ឆ្នាំ ២០១៥ នេះ, ក្របខណ្ឌថវិកាឆ្នាំ ២០១៦ ត្រូវបានរៀបចំឡើង ដោយធ្វើការកំណត់ដូចតទៅ៖

<u>១-ចំណូលថវិកាក្នុងប្រទេសៈ</u> ត្រូវបានគ្រោងចំនួន ១៤ ៣៥៩ ៣៦៩ លានរៀល ស្មើនឹង ១៧,៥៣% នៃ ផសស និងមានកំណើន ២១,៦% ធៀបនឹងច្បាប់ឆ្នាំ២០១៥។ **ក្របខណ្ឌថវិកាឆ្នាំ ២០១៦ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង ១៧,៣៧% នៃ ផសស ដែលមានកំណើនចំនួន ១,៧៨ ពិន្ទុភាគរយ នៃ ផសស ធៀបនឹងច្បាប់ឆ្នាំ ២០១៥** ពោលគឺនឹងសម្រេចបានលើសគោលដៅ ដែលបានដាក់នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ឆ្នាំ២០១៤-២០១៨ ដែលបានកំណត់ថា រាជរដ្ឋាភិបាលត្រូវប្រមូលចំណូល

ចរន្តថវិការដ្ឋឱ្យបានកើនស្មើនឹង **០,៥០ ពិន្ទុភាគរយ នៃ ផសស** ជាប្រចាំឆ្នាំ ក្នុងរយៈពេលមធ្យម។ **ត្រង់ចំណុចនេះ ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា កំណើននៃចំណូលចរន្តថវិការដ្ឋដែលគ្រោងសម្រាប់ឆ្នាំ ២០១៦ និងការអនុវត្តចំណូលដែលសម្រេចបានល្អប្រសើរក្នុងឆ្នាំ ២០១៤ ហើយអាចនឹងបន្តសម្រេចបានទៀតនៅក្នុងឆ្នាំ ២០១៥ នេះ, គឺជាកំណើនមួយខ្ពស់ មិនធ្លាប់មាននៅក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ ដែលសូម្បីតែមូលនិធិរូបិយវត្ថុអន្តរជាតិ ក៏បានផ្តល់ការវាយតម្លៃខ្ពស់លើសមិទ្ធផលនៃការខិតខំប្រឹងប្រែងនេះផងដែរថា មិនធ្លាប់មានពីមុនមកនៅក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់។ យ៉ាងណាមិញ, នេះគឺជាផលផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងអនុវត្តក្នុងឆន្ទៈប្តូរផ្តាច់ឥតងាករេនូវវិធានការមុតស្រួចទាំងឡាយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលបានចាប់ផ្តើមតាំងពីនីតិកាលមុនៗមក នៅក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត ក៏ដូចជាការគាំទ្រ និងត្រួតពិនិត្យតាមដានជាប់ជាប្រចាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

<u>២-ចំណាយសរុបថវិការដ្ឋ:</u> ត្រូវបានគ្រោងចំនួន ១៨ ២៨៣ ៧១៩លានរៀល ស្មើនឹង ២២,៣២% នៃ ផសស និងមានកំណើន ១៦,៥% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ក្នុងនោះ ចំណាយចរន្តថវិការដ្ឋត្រូវបានគ្រោងចំនួន ១១ ៨២៥ ៣២៦ លានរៀល ស្មើនឹង ១៤,៤៣% នៃ ផសស និងមានកំណើន ២០,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ។ **ត្រង់នេះ ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា គម្រោងចំណាយបន្ទុកបុគ្គលិកសរុប នៃថវិការដ្ឋឆ្នាំ ២០១៦ នឹងមានទំហំ ៥ ៩២២ ០០២ លានរៀល ឬស្មើនឹង ៥០,០៨% នៃចំណាយចរន្តថវិការដ្ឋ ឬ ត្រូវជាប្រមាណ ៧,២៣% នៃ ផសស។**

IV - អំពីគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

ទី១- អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០១៦ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យស្មើនឹង ១៦,៥២% នៃ ផសស គឺស្មើនឹង ១៣ ៥៣៨ ១២៧ លានរៀល ដែលមានកំណើន ២១,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ។ តាមគោលដៅនេះ ៖

ក- <u>ចំណូលចរន្តថ្នាក់ជាតិ</u> ត្រូវសម្រេចឱ្យបានចំនួន ១៣ ៤០៧ ២៦៣ លានរៀល គឺមានកំណើន ២១,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ត្រូវជា ១៦,៣៦% នៃ ផសស ដែលក្នុងនោះ៖

•**ចំណូលសារពើពន្ធ** ត្រូវសម្រេចឱ្យបានចំនួន ១១ ៩៥៩ ០៥៥ លានរៀល គឺមានកំណើន ២១,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ត្រូវជា ១៤,១% នៃ ផសស ដែលក្នុងនោះ៖

- ចំណូលគយនិងរដ្ឋាករ មានទំហំស្មើនឹង ៨,១១% នៃ ផសស និង មានកំណើន ២៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៥,
- ចំណូលពន្ធដារ មានទំហំស្មើនឹង ៥,៩៩% នៃ ផសស និង មានកំណើន ២១,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៥។

•**ចំណូលមិនមែនសារពើពន្ធ** ត្រូវបានគ្រោងចំនួន ១ ៨៥២ ២០៨ លានរៀល ត្រូវជា ២,២៦% នៃ ផសស។

ខ- ចំណូលមូលធន ត្រូវបានគ្រោងចំនួន ៤ ២០៥ ២១៤លានរៀល គឺមានកំណើន ២,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ត្រូវជា ៥,១៣% នៃ ផសស។

ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

ក. ចំណាយចរន្តថវិកាថ្នាក់ជាតិ

ថវិកាថ្នាក់ជាតិឆ្នាំ ២០១៦ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្តឱ្យស្ថិតក្នុងកម្រិតចំនួន ១១ ១៥៦ ៩៨៩ លានរៀល គឺមានកំណើន ២០,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ត្រូវជា ១៣,៦២% នៃ ផសស ដែលក្នុងនោះ ៖

ក-១-ចំណាយលើបន្ទុកបុគ្គលិកៈ មានកំណើន ២៣,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ត្រូវជា ៦,៨៨% នៃ ផសស។ បន្ថែមលើរបាយការណ៍ពាក់ព័ន្ធនឹងចំណុចនេះរបស់ **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប**, ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា អាទិភាពនៃចំណាយនេះ ត្រូវបានផ្តោតលើការគ្រោងសម្រាប់ៈ **(១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ១២,០% ដោយអនុវត្តចាប់ពី ខែ មករា ឆ្នាំ ២០១៦** និង **(២)-ការដំឡើងប្រាក់បំណាច់មុខងារដែលនឹងត្រូវអនុវត្តចាប់ពីខែ មេសា ឆ្នាំ ២០១៦ ។** តាមរយៈវិធានការនេះ ស្ថានភាពបៀវត្សអប្បបរមារបស់មន្ត្រីរាជការគ្រប់ប្រភេទ នឹងត្រូវបានផ្លាស់ប្តូរដូចតទៅ៖

ទី១. សម្រាប់មន្ត្រីរាជការស៊ីវិលៈ

-បៀវត្សមន្ត្រីរាជការស៊ីវិល ដែលមិនមែនជាគ្រូបង្រៀន ឬគ្រូពេទ្យ នឹងត្រូវដំឡើងពីជាង ៥៥ ម៉ឺនរៀល ដល់ប្រមាណជាង ៧០ ម៉ឺនរៀល;

-បៀវត្សគ្រូបង្រៀន និងគ្រូពេទ្យ នឹងត្រូវដំឡើងពីជាង ៦៤ ម៉ឺនរៀល ដល់ប្រមាណជាង ៨០ ម៉ឺនរៀល;

ទី២. សម្រាប់កងកម្លាំងប្រដាប់អាវុធៈ

-បៀវត្សនគរបាល (ពលបាលត្រី) នឹងត្រូវដំឡើងពី ៦៤ ម៉ឺនរៀល ដល់ប្រមាណជាង ៧៨ ម៉ឺនរៀល (គិតបញ្ចូលរបបអង្គរ);

-បៀវត្សយោធិន (ពលទោ) នឹងត្រូវដំឡើងពីជាង ៥៣ ម៉ឺនរៀល ដល់ប្រមាណជាង ៧៣ ម៉ឺនរៀល (គិតបញ្ចូលរបបអង្គរ);

ទី៣. ជាមួយគ្នានេះដែរ ប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យា នឹងត្រូវដំឡើងពី ១៦ ម៉ឺនរៀល ដល់ ៤០ ម៉ឺនរៀល ចាប់ពីខែ មករា ឆ្នាំ ២០១៦ ។ ចំពោះនិវត្តជន, ទាំងជាមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ក៏មានការគ្រោងថវិកាប្រមាណ ៣០ ប៊ីលានរៀលផងដែរ សម្រាប់ដំឡើងសោធនកម្រិតទាបបំផុតជាជំហានៗឱ្យដល់ ៤៨ ម៉ឺនរៀល ក្នុង ១ ខែ នៅក្នុងឆ្នាំ ២០១៨។

ក-២-<u>ចំណាយក្រៅបន្ទុកបុគ្គលិកៈ</u> មានកំណើន ១៧,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ត្រូវជា ៦,៧៤% នៃ ផសស ។

ជារួម ចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ឆ្នាំ ២០១៦ ត្រូវបានវិភាជន៍ ដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់ រួមទាំងការអនុវត្តនូវគោលការណ៍ថ្មីមួយចំនួន ទៅតាមវិស័យនីមួយៗ ស្របតាមគោលការណ៍នៃការរៀបចំថវិកា ដូចដែលខ្ញុំបាទបានលើកឡើងពីខាងដើម។ ទន្ទឹមនឹងនេះ, អាទិភាពចំណាយសំខាន់ៗ តាមវិស័យនីមួយៗ ក៏មានគូសបញ្ជាក់ពិស្តារនៅក្នុងខ្លឹមសារនៃអត្ថបទសេចក្តីថ្លែងហេតុរបស់រាជរដ្ឋាភិបាល ហើយឯកឧត្តមប្រធានគណៈកម្មការទី២ ក៏បានលើកឡើងបន្ថែមទៀតអម្បាញ់មិញនេះផងដែរ។ ដូច្នេះ ដើម្បីបានចំណេញពេលថែមទៀត ខ្ញុំបាទសូមមិនអធិប្បាយលម្អិតឡើងវិញទេ, ក៏ប៉ុន្តែគ្រាន់តែសូមធ្វើការគូសរំលេច ដូចខាងក្រោមៈ

ទី១. វិស័យសង្គមកិច្ចនៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទី១ ដោយក្នុងនោះការយកចិត្តទុកដាក់ត្រូវបានផ្តោតជាពិសេសលើក្រសួងអាទិភាពចំនួន ០៣ គឺ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល។ **ជានិន្នាការ ចំណាយចរន្តរបស់វិស័យនេះមានការកើនឡើងខ្លាំងជាងគេ** ពោលគឺមានកំណើន ១៩,៧២% ធៀបនឹងច្បាប់ឆ្នាំ ២០១៥, ហើយទទួលបានកញ្ចប់ថវិកាចំណាយចរន្តក្នុងទំហំស្មើនឹង ៥,២៤% នៃ ផសស។

ទី២. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ មានកំណើន ១៩,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៥, ហើយទទួលបានកញ្ចប់ថវិកាចំណាយចរន្តក្នុងទំហំស្មើនឹង ៣,៣៨% នៃ ផសស។ **ប៉ុន្តែចំណាយបន្ទុកបុគ្គលិកមានចំនួន ៧៤% នៃចំណាយសរុប។**

គួរគូសបញ្ជាក់ផងដែរថា កត្តាដែលធ្វើឱ្យចំណាយចរន្តរបស់វិស័យនេះ មានការកើនឡើងខ្ពស់ (ក្រៅពីបន្ទុកបុគ្គលិក) គឺដោយសារចំណាយលើការផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងការបង្កើនថវិកា សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, សាលាជំរះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ។

ទី៣. វិស័យរដ្ឋបាលទូទៅ មានកំណើន ២១,០ % ធៀបនឹងច្បាប់ឆ្នាំ ២០១៥, ហើយទទួលបានកញ្ចប់ថវិកាចំណាយចរន្តក្នុងទំហំស្មើនឹង ១,៩៥% នៃ ផសស ក្នុងនោះ កញ្ចប់ថវិការបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានកំណើន ៧៦៣,៥%។ ត្រង់នេះ ខ្ញុំបាទសូមគូសបញ្ជាក់ថា កំណើនថវិកាខាងលើនេះ នៅមិនទាន់រាប់បញ្ចូលគម្រោងចំណាយចំនួន ៣៥ ប៊ីលានរៀលផ្សេងទៀត ដែលកំពុងស្នើហិរញ្ញប្បទានពីដៃគូបរទេសនៅឡើយទេ។

ទី៤. វិស័យសេដ្ឋកិច្ច មានកំណើន ១៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ហើយទទួលបានកញ្ចប់ថវិកាចំណាយចរន្តក្នុងទំហំស្មើនឹង ១,៤១% នៃ ផសស។

ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

គម្រោងចំណាយមូលធនថ្នាក់ជាតិឆ្នាំ ២០១៦ មានសមាមាត្រ ៣៦,១% នៃចំណាយថវិកាថ្នាក់ជាតិសរុប និង មានកំណើន ៩,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ត្រូវជា ៧,៦៩% នៃ ផសស ក្នុងនោះ ៖

- គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ មានកំណើន ២០,០% ធៀបនឹងច្បាប់ឆ្នាំ២០១៥ ហើយត្រូវជា ១,៤៩% នៃ ផសស ។ **គួរគូសបញ្ជាក់ផងដែរថា ការកើនឡើងនៃចំណាយវិនិយោគដោយថវិកាជាតិ គឺការឆ្លុះបញ្ចាំងពីការកើនឡើងនៃសមត្ថភាព និងឯករាជ្យភាពខាងថវិការបស់កម្ពុជា។**
- គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសមានកំណើន ៥,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៥ ហើយមានទំហំស្មើនឹង ៤,៧២% នៃ ផសស **ប៉ុន្តែក្នុងនោះ ហិរញ្ញប្បទានឥតសំណងមានការធ្លាក់ចុះខ្លះ** ។

V - អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៦

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក និង ឃុំ-សង្កាត់ មានឱនភាពថវិកាចំនួន ៥១៣ ២៨៣ លានរៀល ហើយនឹងត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់

ជាតិ ដែលការឧបត្ថម្ភនេះមានកំណើន ១៥,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៥, ត្រូវជា ០,៦៣% នៃ ផសស ។

អាទិភាពចំណាយ ត្រូវបានផ្តល់ជាពិសេស ដល់ការតម្លើងប្រាក់បៀវត្ស ជូនដល់ក្រុមប្រឹក្សារាជធានី ខេត្ត, ក្រុង ស្រុក ខ័ណ្ឌ, ឃុំ សង្កាត់ និង មន្ត្រីភូមិ ដោយចាប់ពីខែមេសា ឆ្នាំ ២០១៦ ទៅ នឹងមានស្ថានភាពដូចខាងក្រោមៈ

- ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត នឹងត្រូវដំឡើងពី ១ លានរៀល ដល់ ១លាន ៩ម៉ឺនរៀល, ហើយ ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នឹងត្រូវដំឡើងពី ៨០ម៉ឺនរៀល ដល់ ៨៧ម៉ឺនរៀល;
- ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខ័ណ្ឌ នឹងត្រូវដំឡើងពី ៧០ ម៉ឺនរៀល ដល់ ៨១ ម៉ឺនរៀល, ហើយប្រាក់បំណាច់សមាជិកក្រុមប្រឹក្សា ក្រុង ស្រុក ខ័ណ្ឌ នឹងត្រូវដំឡើងពី ៥០ ម៉ឺនរៀល ដល់ ៦៥ ម៉ឺនរៀល;
- ប្រាក់បំណាច់មេឃុំ ចៅសង្កាត់ នឹងត្រូវដំឡើងពី ៥៧ ម៉ឺនរៀល ដល់ ៧៥ ម៉ឺនរៀល, ប្រាក់បំណាច់ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ នឹងត្រូវដំឡើងពី ៤០ ម៉ឺនរៀល ដល់ ៥៥ ម៉ឺនរៀល ហើយប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវដំឡើងពី ៣៥ ម៉ឺនរៀល ដល់ ៤៨ ម៉ឺនរៀល;
- ប្រាក់បំណាច់ប្រធានភូមិ នឹងត្រូវដំឡើងពី ១៦ ម៉ឺនរៀល ដល់ ២០ ម៉ឺនរៀល, ប្រាក់បំណាច់ជំនួយការភូមិនឹងត្រូវដំឡើងពី ១៤ ម៉ឺនរៀល ដល់ ១៦ ម៉ឺនរៀល និងប្រាក់បំណាច់សមាជិកភូមិនឹងត្រូវដំឡើងពី ១២ ម៉ឺនរៀល ដល់ ១៤ ម៉ឺនរៀល។

VI - អំពីតុល្យភាពរួមនៃថវិកាឆ្នាំ ២០១៦

នៅក្នុងក្របខណ្ឌថវិកាខាងលើ, ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, រាជរដ្ឋាភិបាល អាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ ២,៩៣% នៃ ផសស នៅឆ្នាំ ២០១៦ នេះ ធៀបនឹង ២,៥% នៃ ផសស គ្រោងក្នុងច្បាប់ឆ្នាំ ២០១៥។ ជាលទ្ធផល, គឺថាឱនភាពថវិកាជាតិសរុបស្មើនឹង -៤,៧៩% នៃ ផសស គឺធ្លាក់ចុះពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៥ ដែលស្មើនឹង -៥,១៩% នៃ ផសស។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៤,៧២% នៃ ផសស និង មូលនិធិទ្រទ្រង់ថវិកាប្រមាណជា ០,២៥% នៃ ផសស ។ **ជាតុល្យភាពរួម, សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ មិនត្រឹមតែអាចធានាបានតុល្យភាពថវិកាប៉ុណ្ណោះទេ តែ**

ថែមទាំងបានគ្រោងសម្រេចអតិរេកថវិកាចំនួនប្រមាណ ១៥០ ប៊ីលានរៀល ស្មើនឹង ០,១៨% នៃ ផសស សម្រាប់បង្កើនប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលទៀតផង។

ត្រង់ចំណុចនេះ ខ្ញុំបាទសូមគូសបញ្ជាក់អំពីមូលហេតុ នៃការបង្កើនពិដាននៃការខ្ចីពីបរទេស ពី ៦០០ លានអេសដេអ៊ែរ ទៅ ៧០០ លានអេសដេអ៊ែរ ដើម្បីហិរញ្ញប្បទានឱនភាពដែលត្រូវបានគ្រោង ស្មើនឹង ៤,៧២% នៃ ផសស ដូចខាងក្រោម៖

១-ផ្អែកលើលទ្ធផលនៃការសិក្សា និងការវាយតម្លៃជាបច្ចេកទេស, ទាំងដោយកម្ពុជាខ្លួនឯង ទាំងដោយស្ថាប័នអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម គឺកម្ពុជាមានសមត្ថភាពក្នុងការខ្ចីថ្មីបន្ថែម ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ ក្នុងរង្វង់ពី ៧០០ លាន រហូតទៅដល់ ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ។ ត្រង់ចំណុចនេះ ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា ទោះបីការខ្ចីថ្មីបន្ថែមនេះ អាចនឹងធ្វើឱ្យទំហំសន្និធិបំណុលជាទឹកប្រាក់កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក្តី ក៏ប៉ុន្តែស្ថានភាពបំណុលសាធារណៈ កម្ពុជានៅតែមាន "**ចីរភាព**" និង "**ហានិភ័យកម្រិតទាប**" ដដែល **ហើយកម្ពុជាក៏នឹងមិនជួបប្រទះនូវបញ្ហាបំណុលវ័ណ្ឌកនោះដែរ**។ ផ្អែកលើមូលដ្ឋាននេះ, ទើបនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៥-២០១៨ រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីថ្មីបន្ថែម សម្រាប់ឆ្នាំ២០១៦ ក្នុងរង្វង់ ៧០០ លានអេសដេអ៊ែរ ហើយនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ក៏បានកំណត់នូវទំហំនៃការខ្ចីក្នុងកម្រិត ៧០០ លានអេសដេអ៊ែរ តាមនោះដែរ។

២-ការបង្កើនពិដាននៃការខ្ចីថ្មីបន្ថែមនេះ គឺដើម្បីប៉ះប៉ូវផងដែរការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍ។ ការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណងនេះ កើតមានឡើងដោយសារៈ ម្យ៉ាង, ប្រទេសកម្ពុជាយើងមានកម្រិតអភិវឌ្ឍន៍ខ្ពស់ជាងមុន ដែលធ្វើឱ្យដៃគូអភិវឌ្ឍងាកមកផ្តល់ឥណទានសម្បទានជាជំនួសវិញកាន់តែច្រើន, និងម្យ៉ាងទៀត, ប្រទេសដែលធ្លាប់តែផ្តល់ហិរញ្ញប្បទានឥតសំណងមួយចំនួន ក៏កំពុងតែជួបការលំបាកផ្ទាល់ខ្លួនរបស់គេផងដែរ។

៣-ការខ្ចីថ្មីរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ ២០១៦ មានគោលដៅផ្តល់ហិរញ្ញប្បទានដល់កម្មវិធី/គម្រោងក្នុងវិស័យអាទិភាព សំដៅទ្រទ្រង់ចីរភាពកំណើន និងបង្កើនផលិតភាពសេដ្ឋកិច្ចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ២០១៦-២០១៨ ដូចជា វិស័យធារាសាស្ត្រ, វិស័យគមនាគមន៍ និងដឹកជញ្ជូន និងវិស័យអាទិភាពផ្សេងៗទៀត ជាពិសេស វិស័យអគ្គិសនី ដើម្បីពង្រីកវិសាល-

ភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះតម្លៃអគ្គិសនីនៅជនបទ មកនៅត្រឹមរង្វង់ ៨០០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង។

៤-មានការគម្រោងធ្វើប្រក្រតីកម្មកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍ចាស់ឡើងវិញ ពោលគឺធនាគារពិភពលោក តាមរយៈការទទួលបានឥណទានដែលមានកម្រិតសម្បទានខ្ពស់ រួមមានអត្រាការប្រាក់ ០,៧៥% ក្នុងមួយឆ្នាំ និងរយៈពេលសង ៤០ឆ្នាំ ក្នុងនោះ រយៈពេលអនុគ្រោះ ១០ឆ្នាំ សម្រាប់ហិរញ្ញប្បទានគម្រោងអាទិភាពមួយចំនួន ដែលយើងកំពុងធ្វើការពិភាក្សាគ្នា។

៥- ការបង្កើនពិដាននៃការខ្ចីថ្មីបន្ថែមដល់ ៧០០ លានអេសដេអ៊ែរនេះ គ្រាន់តែជាការគ្រោងប៉ុណ្ណោះ។ ការអនុវត្តជាក់ស្តែង គឺអាចមិនដល់ពិដានឥណទានអនុញ្ញាតដោយច្បាប់នោះទេ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងចំនួនប្រមាណ **៥១៩ លានអេសដេអ៊ែរ** ធៀបនឹងច្បាប់អនុញ្ញាត **៦០០ លានអេសដេអ៊ែរ**, ក្នុងឆ្នាំ២០១៤ ចំនួនប្រមាណ **៥១១ លានអេសដេអ៊ែរ** ធៀបនឹងច្បាប់អនុញ្ញាត **៦០០ លានអេសដេអ៊ែរ**, និងក្នុងឆ្នាំ២០១៥នេះ អាចមានចំនួនប្រមាណ **៥៦០ លាន អេសដេអ៊ែរ** ធៀបនឹងច្បាប់អនុញ្ញាត **៦០០ លានអេសដេអ៊ែរ**។

VII - អំពីបញ្ហាប្រឈមក្នុងការអនុវត្តថវិកាឆ្នាំ ២០១៦

ការអនុវត្តនូវក្របខណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំជម្នះនូវការលំបាក និងបញ្ហាប្រឈមមួយចំនួន ទាំងផ្នែកចំណូល ទាំងផ្នែកចំណាយ។ បញ្ហាប្រឈមចម្បងពាក់ព័ន្ធនឹងផ្នែកចំណូល គឺៈ ចំណូលនៅមិនទាន់អាចឆ្លើយតបនឹងទំហំនៃសេចក្តីត្រូវការផ្នែកចំណាយនៅឡើយ ទោះបីមានការខិតខំប្រឹងប្រែងក្នុងការកៀគរចំណូលគួរឱ្យកត់សម្គាល់យ៉ាងណាក្តី។ លើសពីនេះ ការគ្រោងចំណូលសារពើពន្ធត្រូវបានធ្វើឡើងនៅក្នុងសេណារីយ៉ូសុទិដ្ឋិនិយមកម្រិតខ្ពស់ គួបផ្សំនឹងការធ្លាក់ចុះកាន់តែច្រើននូវចំណូលពន្ធគយ ដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ហើយការទប់ស្កាត់អំពើរត់ពន្ធ និងការគេចវេសពន្ធគ្រប់រូបភាព នៅបន្តជួបប្រទះការលំបាកច្រើន។ រីឯផ្នែកចំណាយវិញ គឺសម្ពាធនៃចំណាយ, ទាំងចំណាយបន្ទុកបុគ្គលិក, ទាំងចំណាយក្រៅបន្ទុកបុគ្គលិក, បានកើនឡើងឥតឈប់ឈរ ដោយសារម្ខាងការផ្តល់អាទិភាពចាំបាច់បំផុតដល់ការដំឡើងបៀវត្សជូនមន្ត្រីរាជការ ក្នុងគោលដៅឆ្ពោះទៅរកបៀវត្សអប្បបរមាជាង ១លានរៀល នៅឆ្នាំ ២០១៨ និងម្ខាងទៀត គឺការបង្កើនចំណាយមួយចំនួនដែលមានភាពចាំបាច់ខ្លាំង ដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសការអនុវត្តសកម្មភាពការកែទម្រង់គ្រប់

វិស័យ និងការវិនិយោគទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ជាមួយគ្នានេះ, សមត្ថភាពស្ថាប័នរដ្ឋក៏នៅមានកម្រិតនៅឡើយ ជាពិសេស សមត្ថភាពរបស់មន្ត្រីពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តថវិកា ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

VIII - **អំពីវិធានការក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៦**

ដើម្បីជម្នះបញ្ហាប្រឈមទាំងឡាយ ទាំងក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និងថវិកាខាងលើប្រកបដោយប្រសិទ្ធភាព ព្រមទាំងមានលក្ខណៈជាប្រព័ន្ធ និងដើម្បីសម្រេចបានតាមគោលដៅនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ដូចបានគូសបញ្ជាក់ខាងលើ, រាជរដ្ឋាភិបាលបានកំណត់វិធានការដាក់លាក់សម្រាប់អនុវត្ត ដូចបានគូសបញ្ជាក់នៅក្នុងអត្ថបទនៃសេចក្តីថ្លែងហេតុ ភ្ជាប់ជាមួយនឹងសេចក្តីព្រាងច្បាប់នេះ ។ ហេតុនេះ ដើម្បីចំណេញពេល ខ្ញុំបាទសូមមិនអធិប្បាយលម្អិតឡើងវិញទេ, ក៏ប៉ុន្តែខ្ញុំបាទសូមអនុញ្ញាតគូសរំលេច **អំពីវិធានការបន្ថែមខាងផ្នែកពន្ធដារសម្រាប់ឆ្នាំ ២០១៦** ដូចតទៅ៖

ក្នុងគោលបំណងធានាប្រសិទ្ធភាព ក្នុងការជំរុញកៀរគរចំណូលឆ្នាំ ២០១៦ ឱ្យទទួលបានលទ្ធផលតាមគោលដៅដែលបានគ្រោងទុក និងដើម្បីធានាឱ្យការគ្រប់គ្រងចំណូលពន្ធមានតម្លាភាព គណនេយ្យភាព និងសង្គតិភាព ព្រមទាំងដើម្បីផ្តល់ការលើកទឹកចិត្តដល់សហគ្រាសតូចៗពិសេសសម្រាលបន្ទុកប្រជាពលរដ្ឋ និងប្រជាកសិករ ដែលមានប្រាក់ចំណូលទាប, រាជរដ្ឋាភិបាលបានដាក់ចេញនៅក្នុងក្របខណ្ឌនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ នេះ នូវវិធានការដូចខាងក្រោម៖

ទី១. ធ្វើវិសោធនកម្មមាត្រា ៤ នៃច្បាប់ស្តីពីសារពើពន្ធ ដើម្បីលុបចោលរបបពន្ធម៉ៅ-ការ ដោយបង្កើតរបបកំណត់ពន្ធតែមួយ គឺរបបស្វ័យប្រកាស ដោយបែងចែកអ្នកជាប់ពន្ធជាបីប្រភេទគឺៈ ១.អ្នកជាប់ពន្ធតូច, ២.អ្នកជាប់ពន្ធមធ្យម និង ៣.អ្នកជាប់ពន្ធធំ។ ការលុបចោលរបបពន្ធម៉ៅការនេះ គឺដើម្បីបញ្ចប់នូវបញ្ហាស្មុគស្មាញមិនចេះចប់ជាមួយអ្នកជាប់ពន្ធតូចតាច ដែលប្រកបរបរអាជីវកម្មគ្រាន់តែដើម្បីចិញ្ចឹមជីវិតផង និងលុបបំបាត់កន្លែងលាក់ខ្លួនរបស់អ្នកជាប់ពន្ធដែលត្រូវបញ្ចូលក្នុងរបបស្វ័យប្រកាសផង។

ទី២. ធ្វើវិសោធនកម្មមាត្រា ៦ នៃច្បាប់ស្តីពីសារពើពន្ធ ដើម្បីកំណត់នូវវិធានគណនេយ្យសម្រាប់អ្នកជាប់ពន្ធទាំងបីប្រភេទ ដោយក្នុងនោះ អ្នកជាប់ពន្ធតូចត្រូវប្រើវិធានគណនេយ្យសាមញ្ញ ហើយអ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា។ ការកំណត់វិធានគណនេយ្យខាងលើ គឺដើម្បី

គាំទ្រដល់ការលុបចោលរបបម៉ៅការ និងជួយបង្កលក្ខណៈងាយស្រួលដល់ម្ចាស់សហគ្រាសតូចៗក្នុងការកាន់កាប់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ។

ទី៣. ធ្វើវិសោធនកម្មទៅលើទំហំប្រាក់ពន្ធប៉ាតង់ដែលបានចែងក្នុងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដើម្បីកំណត់ឡើងវិញនូវទំហំទឹកប្រាក់ត្រូវបង់ឱ្យស្របទៅតាមការវិវឌ្ឍន៍នៃសេដ្ឋកិច្ចបច្ចុប្បន្ន និង ដើម្បីធ្វើឱ្យការកំណត់ពន្ធនេះកាន់តែមានលក្ខណៈសាមញ្ញ, ងាយយល់, ងាយអនុវត្ត និងមានសមធម៌ ពិសេសចំពោះសហគ្រាសតូចៗ។

ទី៤. លុបចោលប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះមួយចំនួនដូចខាងក្រោម៖

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត ដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប,
- ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល ដើម្បីបន្តលើកស្ទួយដល់វិស័យកសិកម្ម ពិសេសដើម្បីលើកទឹកចិត្ត និងសម្រាលបន្ទុករបស់កសិករ,
- ជលយានយន្តធុនតូច ដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋដែលប្រើប្រាស់ជលយានយន្តទាំងនោះជាមធ្យោបាយដឹកជញ្ជូន និងប្រកបអាជីវកម្មជាលក្ខណៈគ្រួសារ។

ទី៥. កែសម្រួលនិងកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ ចំពោះរថយន្តដឹកទំនិញ និង រ៉ឺម៉កសណ្តោង ដែលជាប្រភេទរថយន្តធុនធ្ងន់ ដែលធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងបរិស្ថាន និងដើម្បីប៉ះប៉ូវចំណូលដែលបាត់បង់ពីការលុបចោលពន្ធខាងលើ។

IX- សេចក្តីសន្និដ្ឋាន

ទោះបីជាត្រូវបន្តជួបប្រទះនឹងបញ្ហាប្រឈម, ការស្មុគស្មាញ និងមានហានិភ័យ ព្រមទាំងនៅមានចំណុចខ្វះខាតមួយចំនួនទៀតក្តី, ក៏ថវិកាឆ្នាំ២០១៦ ឆ្លុះបញ្ចាំងពីការបង្កើនជាសារវន្តនូវប្រសិទ្ធភាពនៃការរៀបចំ និងការវិភាជថវិកាក្នុងការឆ្លើយតបទៅនឹងអាទិភាពគោលនយោបាយសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៥ នៃរដ្ឋសភា ជាពិសេស ដើម្បីជំរុញការបញ្ចេញលទ្ធផលជាក់ស្តែងជូនប្រជាជន។ **ដូច្នេះ យើងអាចនិយាយបានថា ថវិកាឆ្នាំ ២០១៦ គឺពិតជាដើរតួនាទីជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពប្រាកដមែន។**

សរុបមក ថវិកាឆ្នាំ ២០១៦ អាចប្រសិទ្ធនាមបានថាជា **“ថវិកានៃការប្រមូលពួតផ្តុំនូវកម្លាំង និងធនធាន សំដៅសម្រេចបាននូវសមិទ្ធផលសំខាន់ៗបន្ថែមទៀត ដើម្បីធានាបាននូវដំណើរផ្លាស់ប្តូរមួយ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព ដោយផ្សារភ្ជាប់ការគិតគូរអំពីតុល្យភាពនៃកំណើនសេដ្ឋកិច្ច និងការបែងចែកផលនៃកំណើននេះ ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា និងនិន្នាការពិភពលោក និងតំបន់ ដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅកាន់ត្រើយសុខសន្តិភាពយូរអង្វែង វិបុលភាព និងយុត្តិធម៌សង្គម”**។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេចអគ្គមហាពញាចក្រី និងអង្គសភាទាំងមូល មេត្តាពិនិត្យនិងផ្តល់ការអនុម័តលើសេចក្តីព្រាង**ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់-គ្រងឆ្នាំ២០១៦** ដោយអនុគ្រោះ។

សូមអរគុណ